ក្រសួងអប់រំ យុវជន និងកីឡា

សៀវភៅពន្លឿនការសិក្សា

# គណិតវិទ្យា

## ថ្នាក់ឆ្នាំទី ៣




សម្រាប់គ្រូបង្រៀន

ព.ស. ២៥៥៨ គ.ស. ២០១៤



ក្រសួងអប់រំ យុវជន និងកីឡា

# សៀវភៅពន្យឿនការសិក្សា

# គណិតវិទ្យា

# ថ្នាក់ឆ្នាំទី ៣

## ឯកសារសម្រាប់គ្រូ

**បោះពុម្ពលើកទី ២**
**ឆ្នាំ ២០១៥**

**គណៈកម្មការត្រួតត្រង**

| | |
|---|---|
| ឯកឧត្តម ណាត ប៊ុនរឿន | លោក អ៊ុក សុវណ្ណ |
| ឯកឧត្តម អ៊ឹម កុច | លោក ចាន់ សុភា |
| ឯកឧត្តម សំ សេរីរតន៍ | លោក ជា វណ្ណេត |

**គណៈកម្មការនិពន្ធ**

| | |
|---|---|
| លោកស្រី ទូច សុភាព | លោកស្រី ឡាច កញ្ញា |
| លោកស្រី ហ៊ុន សុជាតិ | លោក ធន់ សាមិត្ត |
| លោកស្រី សាន ណារ៉ា | លោក សួន សាម៉ែត |
| លោកស្រី ចក់ វណ្ណា | |

**អ្នករៀបរៀងនិងរចនាចំពីរ**

| | |
|---|---|
| លោកស្រី ខ្វង់ គឹមទូច | លោក អាន រ៉ូប្រាវ |

**គណៈកម្មការត្រួតពិនិត្យ**

| | |
|---|---|
| លោក ជា វណ្ណេត | លោកស្រី ខ្វង់ គឹមទូច |
| លោក អាន រ៉ូប្រាវ | លោកស្រី មិន វិចិត្រា |

# បញ្ជីអត្ថបទ


អារម្ភកថា ..... ១
ផ្នែកទី១៖ បំណែងចែកកម្មវិធីសិក្សា ..... ២
ផ្នែកទី២៖ លំនាំនៃការបង្រៀន ..... ១០
ផ្នែកទី៣៖ សលាកប័ត្រជំពូកនិងមេរៀន ..... ១៩
ជំពូកទី១ : ចំនួន ..... ២០
ជំពូកទី២ : វិធីគុណវិធីចែក ..... ២៦
ជំពូកទី៣ : ប្រមាណវិធីមានវង់ក្រចក ..... ៣៤
ជំពូកទី៤ : ចំនួនទសភាគ ..... ៣៧
ជំពូកទី៥ : វិធីបូកនិងវិធីដកចំនួនទសភាគ ..... ៤១
ជំពូកទី៦ : វិធីគុណនិងវិធីចែកចំនួនទសភាគ ..... ៤៧
ជំពូកទី៧ : ធរណីមាត្រ ..... ៥០
ជំពូកទី៨ : ប្រភាគ ..... ៥៤
ជំពូកទី៩ : ចំនួនចម្រុះ ..... ៥៩
ជំពូកទី១០ : រង្វាស់ប្រវែង ..... ៦២
ជំពូកទី១១ : រង្វាស់ទម្ងន់ ..... ៦៥
ជំពូកទី១២ : រង្វាស់ចំណុះ ..... ៦៧
ជំពូកទី១៣ : រង្វាស់ពេល ..... ៧០
ជំពូកទី១៤ : បរិមាត្រនិងផ្ទៃក្រឡា ..... ៧៤
ជំពូកទី១៥ : តួចែករួមធំបំផុត ពហុគុណរួមតូចបំផុត ..... ៧៩
ជំពូកទី១៦ : វិធីបូកនិងវិធីដកប្រភាគ ..... ៨៨
ជំពូកទី១៧ : វិធីគុណនិងវិធីចែកប្រភាគ ..... ៩៣
ជំពូកទី១៨ : ការជំនួសលេខដោយអក្សរ ..... ៩៧
ជំពូកទី១៩ : ផលធៀបភាគរយនិងសមាមាត្រ ..... ១០១
ជំពូកទី២០ : ប្រមាណវិធីលើចំនួនចម្រុះ ..... ១០៩
ជំពូកទី២១ : រូបិយវត្ថុនិងការប្រាក់ ..... ១១៤
ជំពូកទី២២ : ស្ថិតិ ..... ១១៧
ជំពូកទី២៣ : មាឌនិងផ្ទៃក្រឡាសូលីត ..... ១២៧
ជំពូកទី២៤ : ប្លង់ ផែនទី និងមាត្រដ្ឋាន ..... ១៣៣

# អារម្ភកថា

ឯកសារជំនួយគ្រូមុខវិជ្ជាគណិតវិទ្យាថ្នាក់ឆ្នាំទី៣នេះ ត្រូវបានរៀបចំឡើងក្រោមកិច្ចសហប្រតិបត្តិការរវាងក្រសួងអប់រំ យុវជន និងកីឡា ជាមួយនឹងអង្គការដើម្បីភាពញញឹមនៃកុមារនៅក្នុងគម្រោងចងក្រងសៀវភៅពន្លឿនការសិក្សាសម្រាប់សាលាបឋមសិក្សា។ ឯកសារនេះ ត្រូវបានចងក្រងឡើងដោយគណៈកម្មការនិពន្ធក្នុងគម្រោងនេះ និងដោយមានការចូលរួមពីលោកគ្រូអ្នកគ្រូដែលបង្រៀនថ្នាក់ពន្លឿនការសិក្សានៅអង្គការដើម្បីភាពញញឹមនៃកុមារ។

ឯកសារនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងសម្រួលដល់ការបង្រៀនមុខវិជ្ជាគណិតវិទ្យាថ្នាក់ឆ្នាំទី៣ របស់លោកគ្រូអ្នកគ្រូ។ ខ្លឹមសារសំខាន់នៃឯកសារនេះ មានការបង្ហាញពីកម្មវិធីពន្លឿនការសិក្សានៅសាលាបឋមសិក្សា លំនាំនៃការបង្រៀនតាមសមត្ថភាពនីមួយៗនិងសលាកបត្រជំពូក និងមេរៀន ពិសេស ផ្តោតទៅលើចម្លើយរបស់សំណួរ និងកំណែលំហាត់ដែលផ្តល់នូវភាពងាយស្រួលសម្រាប់លោកគ្រូអ្នកគ្រូក្នុងការប្រើប្រាស់សៀវភៅពន្លឿនការសិក្សា។

ក្នុងការបង្រៀន គណៈកម្មការយើងមិនទាមទារឱ្យលោកគ្រូអ្នកគ្រូអនុវត្តឯកសារនេះទាំងស្រុងនោះទេ។ ប៉ុន្តែកត្តាសំខាន់គឺជំរុញឱ្យការសិក្សារបស់សិស្សទទួលបានលទ្ធផលល្អប្រពៃ ដោយពឹងផ្អែកលើចំណេះដឹង បទពិសោធក្នុងការរៀបចំវិធីបង្រៀន បំណិនប្រសប់ក្នុងការប្រើប្រាស់វាក្យស័ព្ទ និងសម្ភារឧបទេសក្នុងការបង្រៀនរបស់លោកគ្រូអ្នកគ្រូ។

ក្រោយពីបញ្ចប់មេរៀននីមួយៗ លោកគ្រូអ្នកគ្រូធ្វើរង្វាយតម្លៃលើកម្រិតយល់ដឹងរបស់សិស្ស ដោយធ្វើសំណួរសេរ ឬសំណួរផ្គាល់មាត់ ឬលំហាត់អនុវត្ត ព្រោះវាអាចបង្ហាញឱ្យគ្រូដឹងពីលទ្ធផលបង្រៀន ដើម្បីឱ្យលោកគ្រូអ្នកគ្រូជ្រើសរើសនិងកែសម្រួលវិធីសាស្ត្របង្រៀនឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត។

គណៈកម្មការនិពន្ធសង្ឃឹមថា ឯកសារជំនួយគ្រូគណិតវិទ្យាថ្នាក់ឆ្នាំទី៣នេះ នឹងបានជាប្រយោជន៍ច្រើនដល់ការបង្រៀនរបស់គ្រូ ដើម្បីរួមចំណែកក្នុងការលើកកម្ពស់គុណភាពរៀននិងបង្រៀនប្រកបដោយប្រសិទ្ធភាព។

**គណៈកម្មការនិពន្ធ**

# ផ្នែកទី១
# បំណែងចែកកម្មវិធីសិក្សា

កម្មវិធីសិក្សាថ្នាក់ពន្លឿនការសិក្សា មុខវិជ្ជា គណិតវិទ្យា ថ្នាក់ឆ្នាំទី៣នេះ គឺជាការសំយោគបញ្ចូលគ្នារវាងកម្មវិធីសិក្សា មុខវិជ្ជា គណិតវិទ្យាថ្នាក់ទី៥និងថ្នាក់ទី៦នៃកម្មវិធីសិក្សាគោលរបស់ក្រសួងអប់រំ យុវជន និងកីឡា។ មុខវិជ្ជា គណិតវិទ្យា ថ្នាក់ឆ្នាំទី៣នេះ មានចំនួន១១ម៉ោងសិក្សាក្នុង១សប្តាហ៍ ដែល១ម៉ោងសិក្សាមានរយៈពេល៤០នាទី។

| ជំពូក | មេរៀន | ចំណងជើងមេរៀន | រយៈពេល |
|---|---|---|---|
| ទី១៖ ចំនួន | ១ | អំណាននិងសំណេរចំនួនធំជាង១ ០០០ ០០០ | ១ម៉ |
| | ២ | ការប្រៀបធៀបនិងរៀបលំដាប់ចំនួន | ១ម៉ |
| | ៣ | ខ្នង់និងតម្លៃលេខតាមខ្នង់ | ១ម៉ |
| | ៤ | ការបង្គត់ចំនួន | ១ម៉ |
| | ៥ | ការគណនាមធ្យមនព្វន្ត | ២ម៉ |
| | ៦ | លំហាត់សាឡើងវិញ | ៣ម៉ |
| ទី២៖ វិធីគុណ វិធីចែក | ១ | ការគុណចំនួនមានលេខ4ខ្នង់នឹង2ខ្នង់ | ២ម៉ |
| | ២ | ការគុណចំនួនមានលេខ4ខ្នង់នឹង3ខ្នង់ | ២ម៉ |
| | ៣ | ការដោះស្រាយចំណោទដោយប្រើអង្កត់ | ២ម៉ |
| | ៤ | លំហាត់សាឡើងវិញ | ២ម៉ |
| | ៥ | ការចែកចំនួនមានលេខ4ខ្នង់នឹង3ខ្នង់គ្មានសំណល់ | ២ម៉ |
| | ៦ | ការចែកចំនួនមានលេខ4ខ្នង់នឹង3ខ្នង់មានសំណល់ | ២ម៉ |
| | ៧ | ការចែកដែលផលចែកជាចំនួនទសភាគ | ២ម៉ |
| | ៨ | ការចែកដែលតំណាំងចែកនិងតួចែកមានលេខ0នៅខាងចុង | ១ម៉ |
| | ៩ | លំហាត់សាឡើងវិញ | ២ម៉ |
| | ១0 | ចំណោទ | ៤ម៉ |
| ទី៣៖ ប្រមាណវិធីមានវង់ក្រចក | ១ | ប្រមាណវិធីមានវង់ក្រចក | ២ម៉ |
| | ២ | ប្រមាណវិធីមានវង់ក្រចកនិងឃ្នាប | ២ម៉ |
| | ៣ | លំហាត់សាឡើងវិញ | ២ម៉ |
| | ៤ | ចំណោទ | ២ម៉ |
| ទី៤៖ ចំនួនទសភាគ | ១ | អំណាននិងសំណេរចំនួនទសភាគ | ១ម៉ |
| | ២ | ខ្នង់និងតម្លៃលេខតាមខ្នង់ | ១ម៉ |
| | ៣ | ការប្រៀបធៀបនិងរៀបលំដាប់ចំនួនទសភាគ | ១ម៉ |
| | ៤ | ការបង្គត់ចំនួនទសភាគជាចំនួនគត់ | ១ម៉ |
| | ៥ | ចំនួនទសភាគមានតម្លៃស្មើគ្នា | ១ម៉ |

| | | | |
|---|---|---|---|
| | ៦ | លំហាត់សាឡើងវិញ | ២ម៉ |
| ទី៥៖<br>វិធីបូកនិងវិធីដក<br>ចំនួនទសភាគ | ១ | វិធីបូកចំនួនទសភាគតាមទម្រង់ប្រភាគ | ២ម៉ |
| | ២ | វិធីបូកចំនួនទសភាគនឹងចំនួនគត់ | ១ម៉ |
| | ៣ | វិធីបូកចំនួនទសភាគនឹងចំនួនទសភាគ | ១ម៉ |
| | ៤ | វិធីដកចំនួនទសភាគតាមទម្រង់ប្រភាគ | ២ម៉ |
| | ៥ | វិធីដកចំនួនគត់នឹងចំនួនទសភាគនិងវិធីដកចំនួនទសភាគនឹងចំនួនគត់ | ១ម៉ |
| | ៦ | វិធីដកចំនួនទសភាគនឹងចំនួនទសភាគ | ១ម៉ |
| | ៧ | លំហាត់សាឡើងវិញ | ២ម៉ |
| | ៨ | ចំណោទ | ៤ម៉ |
| ទី៦៖<br>វិធីគុណនិងវិធីចែក<br>ចំនួនទសភាគ | ១ | វិធីគុណចំនួនទសភាគនឹងចំនួនគត់ | ១ម៉ |
| | ២ | វិធីគុណចំនួនទសភាគនឹងចំនួនទសភាគ | ២ម៉ |
| | ៣ | វិធីចែកចំនួនទសភាគនឹងចំនួនគត់ | ២ម៉ |
| | ៤ | វិធីចែកចំនួនគត់នឹងចំនួនទសភាគ | ២ម៉ |
| | ៥ | វិធីចែកចំនួនទសភាគនឹងចំនួនទសភាគ | ២ម៉ |
| | ៦ | លំហាត់សាឡើងវិញ | ២ម៉ |
| | ៧ | ចំណោទ | ៤ម៉ |
| ទី៧៖<br>ធរណីមាត្រ | ១ | បន្ទាត់និងអង្កត់ | ១ម៉ |
| | ២ | ប្រភេទមុំ | ១ម៉ |
| | ៣ | សំណង់មុំដោយប្រើរ៉ាប៉ទ័រ | ១ម៉ |
| | ៤ | ត្រីកោណនិងប្រភេទត្រីកោណ | ១ម៉ |
| | ៥ | សំណង់ត្រីកោណដោយស្គាល់ជ្រុងមួយនិងមុំពីរ | ២ម៉ |
| | ៦ | សំណង់ត្រីកោណដោយស្គាល់ជ្រុងពីរនិងមុំមួយ | ២ម៉ |
| | ៧ | លំហាត់សាឡើងវិញ | ២ម៉ |
| | ៨ | កន្លះបន្ទាត់ពុះមុំ | ២ម៉ |
| | ៩ | សំណង់កន្លះបន្ទាត់ពុះមុំ | ២ម៉ |
| | ១០ | សំណង់មុំ$60^0$ដោយប្រើដៃកឈាននិង បន្ទាត់ | ២ម៉ |
| | ១១ | សំណង់មុំ$90^0$ដោយប្រើដៃកឈាននិង បន្ទាត់ | ២ម៉ |
| | ១២ | លំហាត់សាឡើងវិញ | ២ម៉ |
| ទី៨៖ | ១ | ការសម្រួលប្រភាគ | ២ម៉ |

| | | | |
|---|---|---|---|
| ប្រភាគ | ២ | វិធីបូកនិងវិធីដកប្រភាគមានភាគបែងដូចគ្នា | ២ម៉ោ |
| | ៣ | ការប្តូរប្រភាគតូចជាងឯកតាជាចំនួនទសភាគនិងភាគរយ | ២ម៉ោ |
| | ៤ | វិធីគុណប្រភាគនឹងចំនួនគត់ | ២ម៉ោ |
| | ៥ | វិធីចែកប្រភាគនឹងចំនួនគត់ | ២ម៉ោ |
| | ៦ | លំហាត់សាឡើងវិញ | ២ម៉ោ |
| | ៧ | ចំណោទ | ៤ម៉ោ |
| ទី៩៖<br>ចំនួនចម្រុះ | ១ | ការអាននិងសរសេរចំនួនចម្រុះ | ១ម៉ោ |
| | ២ | ការប្តូរចំនួនចម្រុះជាប្រភាគ | ២ម៉ោ |
| | ៣ | ការប្តូរប្រភាគធំជាងឯកតាជាចំនួនចម្រុះ | ២ម៉ោ |
| | ៤ | ការប្រៀបធៀបនិងរៀបលំដាប់ចំនួនចម្រុះ | ២ម៉ោ |
| | ៥ | លំហាត់សាឡើងវិញ | ២ម៉ោ |
| ទី១០៖<br>រង្វាស់ប្រវែង | ១ | ការប្តូរឯកតានៃរង្វាស់ប្រវែង | ២ម៉ោ |
| | ២ | វិធីបូកនិងវិធីដករង្វាស់ប្រវែង | ២ម៉ោ |
| | ៣ | វិធីគុណនិងវិធីចែករង្វាស់ប្រវែង | ២ម៉ោ |
| | ៤ | លំហាត់សាឡើងវិញ | ២ម៉ោ |
| | ៥ | ចំណោទ | ៤ម៉ោ |
| ទី១១៖<br>រង្វាស់ទម្ងន់ | ១ | ការប្តូរឯកតានៃរង្វាស់ទម្ងន់ | ២ម៉ោ |
| | ២ | វិធីបូកនិងវិធីដករង្វាស់ទម្ងន់ | ២ម៉ោ |
| | ៣ | វិធីគុណនិងវិធីចែករង្វាស់ទម្ងន់ | ២ម៉ោ |
| | ៤ | លំហាត់សាឡើងវិញ | ២ម៉ោ |
| | ៥ | ចំណោទ | ៤ម៉ោ |
| ទី១២៖<br>រង្វាស់ចំណុះ | ១ | ការប្តូរឯកតានៃរង្វាស់ចំណុះ | ២ម៉ោ |
| | ២ | ទំនាក់ទំនងរវាងចំណុះនិងទម្ងន់ | ១ម៉ោ |
| | ៣ | វិធីបូកនិងវិធីដករង្វាស់ចំណុះ | ២ម៉ោ |
| | ៤ | វិធីគុណនិងវិធីចែករង្វាស់ចំណុះ | ២ម៉ោ |
| | ៥ | លំហាត់សាឡើងវិញ | ២ម៉ោ |
| | ៦ | ចំណោទ | ៣ម៉ោ |
| ទី១៣៖<br>រង្វាស់ពេល | ១ | វិធីបូកនិងវិធីដកឯកតារង្វាស់ពេល | ២ម៉ោ |
| | ២ | វិធីគុណរង្វាស់ពេល | ២ម៉ោ |

| | | | |
|---|---|---|---|
| | ៣ | វិធីចែកវង្វាស់ពេល | ២ម៉ោ |
| | ៤ | លំហាត់សាឡើងវិញ | ២ម៉ោ |
| | ៥ | ចំណោទ | ៤ម៉ោ |
| | ៥ | ល្បឿន | ២ម៉ោ |
| | ៦ | ចំណោទ | ៦ម៉ោ |
| ទី១៤៖<br>បរិមាត្រ<br>និងផ្ទៃក្រឡា | ១ | រង្វង់ | ១ម៉ោ |
| | ២ | សំណង់រង្វង់ | ១ម៉ោ |
| | ៣ | បរិមាត្ររង្វង់ ឬថាស | ២ម៉ោ |
| | ៤ | បរិមាត្រចតុកោណកែងនិងបរិមាត្រការេ | ២ម៉ោ |
| | ៥ | ចំណោទ | ២ម៉ោ |
| | ៦ | ឯកតានៃខ្នាតសម្រាប់វាស់ផ្ទៃក្រឡា | ២ម៉ោ |
| | ៧ | ផ្ទៃក្រឡាចតុកោណកែងនិងផ្ទៃក្រឡាការេ | ២ម៉ោ |
| | ៨ | ផ្ទៃក្រឡាត្រីកោណ | ២ម៉ោ |
| | ៩ | ផ្ទៃក្រឡាប្រលេឡូក្រាម | ២ម៉ោ |
| | ១០ | ផ្ទៃក្រឡាចតុកោណញ្ញាយ | ២ម៉ោ |
| | ១១ | ផ្ទៃក្រឡាថាស ឬរង្វង់ | ២ម៉ោ |
| | ១២ | ចំណោទ | ៤ម៉ោ |
| ទី១៥៖<br>តួចែករួមធំបំផុត<br>ពហុគុណរួមតូចបំផុត | ១ | កត្តានៃមួយចំនួន | ២ម៉ោ |
| | ២ | ចំនួនបឋម | ២ម៉ោ |
| | ៣ | ការសរសេរមួយចំនួនជាផលគុណកត្តាបឋម | ២ម៉ោ |
| | ៤ | តួចែករួមធំបំផុត | ២ម៉ោ |
| | ៥ | របៀបរកតួចែករួមធំបំផុតតាមផលគុណកត្តាបឋម | ២ម៉ោ |
| | ៦ | ពហុគុណនៃមួយចំនួន | ២ម៉ោ |
| | ៧ | ពហុគុណរួមតូចបំផុត | ២ម៉ោ |
| | ៨ | របៀបរកពហុគុណរួមតូចបំផុតតាមផលគុណកត្តាបឋម | ២ម៉ោ |
| | ៩ | លំហាត់សាឡើងវិញ | ២ម៉ោ |
| | ១០ | ចំណោទ | ៤ម៉ោ |
| ទី១៦៖<br>វិធីបូកនិងវិធី | ១ | ភាគបែងរួមនៃប្រភាគ | ២ម៉ោ |
| | ២ | របៀបរកភាគបែងរួមតូចបំផុតតាមពហុគុណរួមតូចបំផុត | ២ម៉ោ |

| | | | |
|---|---|---|---|
| ដកប្រភាគ | ៣ | របៀបរកភាគបែងរួមតូចបំផុតតាមផលគុណកត្តាបឋម | ២ម៉ោ |
| | ៤ | វិធីបូកប្រភាគមានភាគបែងខុសគ្នា | ២ម៉ោ |
| | ៥ | វិធីដកប្រភាគមានភាគបែងខុសគ្នា | ២ម៉ោ |
| | ៦ | លំហាត់សាឡើងវិញ | ២ម៉ោ |
| | ៧ | ចំណោទ | ៤ម៉ោ |
| ទី១៧៖ វិធីគុណនិងវិធីចែកប្រភាគ | ១ | វិធីគុណប្រភាគនឹងប្រភាគ | ២ម៉ោ |
| | ២ | វិធីចែកប្រភាគនឹងប្រភាគ | ២ម៉ោ |
| | ៣ | លំហាត់សាឡើងវិញ | ២ម៉ោ |
| | ៤ | ចំណោទ | ៤ម៉ោ |
| ទី១៨៖ ការជំនួសលេខដោយអក្សរ | ១ | ផលបូកតួដូចគ្នា វិធីបូកនិងវិធីដកតួអក្សរ | ២ម៉ោ |
| | ២ | តម្លៃលេខនៃតួអក្សរ | ១ម៉ោ |
| | ៣ | របៀបដោះស្រាយចំណោទ | ២ម៉ោ |
| | ៤ | លំហាត់សាឡើងវិញ | ៣ម៉ោ |
| | ៥ | ចំណោទ | ៤ម៉ោ |
| ទី១៩៖ ផលធៀប ភាគរយ និងសមាមាត្រ | ១ | ផលធៀប | ១ម៉ោ |
| | ២ | ផលធៀបស្មើគ្នា | ១ម៉ោ |
| | ៣ | ភាគរយ | ២ម៉ោ |
| | ៤ | ការគណនាតម្លៃភាគរយនៃមួយចំនួន | ២ម៉ោ |
| | ៥ | លំហាត់សាឡើងវិញ | ២ម៉ោ |
| | ៦ | ចំណោទ | ៤ម៉ោ |
| | ៧ | ផលធៀបទំហំដែលមានឯកតាដូចគ្នា | ២ម៉ោ |
| | ៨ | ផលធៀបទំហំដែលមានឯកតាខុសគ្នា | ២ម៉ោ |
| | ៩ | ប្រភាគនិងភាគរយ | ២ម៉ោ |
| | ១០ | លំហាត់សាឡើងវិញ | ២ម៉ោ |
| | ១១ | ចំណោទ | ៥ម៉ោ |
| | ១២ | សមាមាត្រ | ១ម៉ោ |
| | ១២ | វិធីគុណខ្វែងនៃសមាមាត្រ | ២ម៉ោ |
| | ១៣ | លំហាត់សាឡើងវិញ | ២ម៉ោ |
| | ១៤ | ចំណោទ | ៤ម៉ោ |

| | | | |
|---|---|---|---|
| ទី២០៖<br>ប្រមាណវិធីលើចំនួនចម្រុះ | ១ | វិធីបូកចំនួនចម្រុះ | ២ម៉ោ |
| | ២ | វិធីដកចំនួនចម្រុះ | ២ម៉ោ |
| | ៣ | វិធីគុណចចំនួនចម្រុះ | ២ម៉ោ |
| | ៤ | វិធីចែកចំនួនចម្រុះ | ២ម៉ោ |
| | ៥ | លំហាត់សាឡើងវិញ | ៣ម៉ោ |
| | ៦ | ចំណោទ | ៤ម៉ោ |
| ទី២១ ៖<br>រូបិយវត្ថុនិងការប្រាក់ | ១ | អត្រាប្តូរប្រាក់ | ១ម៉ោ |
| | ២ | អត្រានៃការប្រាក់ | ២ម៉ោ |
| | ៣ | ការបង់រំលស់ | ១ម៉ោ |
| | ៤ | ចំណោទ | ៣ម៉ោ |
| ទី២២៖<br>ស្ថិតិ | ១ | តារាងទិន្នន័យ | ១ម៉ោ |
| | ២ | ក្រាបសសរ | ២ម៉ោ |
| | ៣ | ក្រាបសសរភ្លោះ | ២ម៉ោ |
| | ៤ | ក្រាបខ្សែ | ២ម៉ោ |
| | ៥ | ក្រាបផ្ទៃត | ២ម៉ោ |
| | ៦ | លំហាត់សាឡើងវិញ | ៣ម៉ោ |
| ទី២៣ ៖<br>មាឌនិងផ្ទៃក្រឡាសូលីត | ១ | ឯកតានៃមាឌ | ១ម៉ោ |
| | ២ | រូបមន្តនៃមាឌសូលីត | ១ម៉ោ |
| | ៣ | ទំនាក់ទំនងមាឌនិងចំណុះ | ១ម៉ោ |
| | ៤ | ផ្ទៃក្រឡាប្រអប់ | ២ម៉ោ |
| | ៥ | ផ្ទៃក្រឡាស៊ីឡាំង | ២ម៉ោ |
| | ៦ | លំហាត់សាឡើងវិញ | ២ម៉ោ |
| | ៧ | ចំណោទ | ៥ម៉ោ |
| ទី២៤៖<br>ប្លង់ផែនទីនិងមាត្រដ្ឋាន | ១ | ប្លង់ | ១ម៉ោ |
| | ២ | ប្លង់និងមាត្រដ្ឋាន | ២ម៉ោ |
| | ៣ | ការគណនាចម្ងាយពិត | ២ម៉ោ |
| | ៤ | ចំណោទ | ៣ម៉ោ |

## សរុបម៉ោងក្នុងមួយឆ្នាំសិក្សា

- សរុបម៉ោងទាំងអស់11 ម៉ោង × 38សប្តាហ៍ = 418 ម៉ោងសិក្សា
- សរុបម៉ោងបង្រៀន 349 ម៉ោង
- សរុបម៉ោងសល់ 69 ម៉ោង

# ផ្នែកទី២
# លំនាំនៃការបង្រៀន

ផ្អែកតាមលទ្ធផលសិក្សារបស់សិស្សប៉ុន្មានឆ្នាំកន្លងមកនេះយើងឃើញថា សិស្សបឋមសិក្សាមានមូលដ្ឋាននៃការស្រាវជ្រាវនៅមានកម្រិតទាបគួរឱ្យបារម្ភ។ដើម្បីពង្រឹងគុណភាពនៃការស្រាវជ្រាវឱ្យកាន់តែប្រសើរដោយធ្វើការសម្រប សម្រួលវិធីសាស្ត្រនិងកែលម្អឯកសារបង្រៀនគណិតវិទ្យាថ្នាក់ទី៥និងថ្នាក់ទី៦របស់ក្រសួងអប់រំ យុវជន និងកីឡាមកជាសៀវភៅពន្លឿនការសិក្សា ថ្នាក់ឆ្នាំទី៣ដើម្បីឱ្យសិស្សក្នុងកម្រិតនេះចេះក្នុងទិសដៅឆ្លើយតបទៅនឹងកម្មវិធីពន្លឿនការសិក្សា។ សម្រាប់កម្រិតសិក្សាថ្នាក់ឆ្នាំទី៣នេះ ។

ដើម្បីជាជំនួយដល់ការប្រើប្រាស់សៀវភៅពន្លឿនការសិក្សានេះបានត្រឹមត្រូវគណៈកម្មការបានរៀបចំសេចក្តីណែនាំដោយផ្តោតលើ៖

## ១. ការប្រើប្រាស់សម្ភារៈ

ក្នុងការបង្រៀនលោកគ្រូ អ្នកគ្រូគប្បីប្រើប្រាស់សម្ភារឧបទេស ពីព្រោះវាជាមធ្យោបាយទាក់ទាញអារម្មណ៍សិស្សឱ្យចូលរួមក្នុងបង្រៀននិងការរៀនយ៉ាងមានប្រសិទ្ធិភាព។ ជាពិសេសធ្វើឱ្យសិស្សងាយចងចាំសប្បាយរីករាយតាមរយៈការលើកបង្ហាញ ពណ៌នា និងល្បែងសិក្សា។

## ២. ជំនាំនៃការបង្រៀន

### ២.១.ជំនាំនៃការបង្រៀនឆ្នាំ

**ចិចបូកនិងចិចដកប្រភាគមានភាគបែងដូចគ្នា**( 2ម៉ោង )

### ក. ចិចបូកប្រភាគ

**សកម្មភាពទី១៖ ដាក់បញ្ហា**

- ទំនាក់ទំនង
- ដាក់បញ្ហាផ្ទាល់មាត់ *ដើម្បីបូកប្រភាគមានភាគបែងដូចគ្នាតើត្រូវធ្វើដូចម្តេច?*

ចូររកផលបូក $\frac{1}{5}+\frac{2}{5}=$ ☐

- សួរឡើងវិញពីបញ្ហាតើអ្នកគ្រូនិយាយដូចម្តេចអម្បាញ់មិញ?
- សរសេរឬបិទបញ្ហាលើក្តារខៀន

បញ្ហា៖ *ដើម្បីបូកប្រភាគមានភាគបែងដូចគ្នាតើត្រូវធ្វើដូចម្តេច? ចូររកផលបូក* $\frac{1}{5}+\frac{2}{5}=$ ☐

- ឱ្យសិស្សអានបញ្ហា
- សួររកវត្ថុបំណងនៃបញ្ហា តើបញ្ហានេះចង់ឱ្យប្អូនធ្វើដូចម្តេច? (រកផលបូកប្រភាគ)
- កែតម្រូវចម្លើយ

**សកម្មភាពទី២៖ ប៉ាន់ស្មាន**

- ឱ្យសិ្សសប៉ាន់ស្មាន
- កត់ត្រាចម្លើយប៉ាន់ស្មានលើក្តារខៀន( $\frac{3}{5}$ , $\frac{5}{3}$ )
- សួរបញ្ជាក់ពីចម្លើយរបស់សិស្ស តើប្អូនដឹងថាការប៉ាន់ស្មាននេះដឹងថាត្រឹមត្រូវឬទេ? ដូចនេះដើម្បីឱ្យដឹងថាការប៉ាន់ស្មានរបស់យើងនេះខុសឬត្រូវ? តើត្រូវធ្វើដូចម្តេច?
- ដឹកនាំសិស្សពិភាក្សាក្រុមស្រាវជ្រាវតាមរយៈរូបភាព

**សកម្មភាពទី៣៖ ពិភាក្សាស្រាវជ្រាវ**

- បង្ហាញសម្ភារៈដូចជា៖ រូបភាពប្រភាគ ហ្វឺត ក្រដាសA3...
- ណែនាំរបៀបពិភាក្សៈតាមរយៈរូបភាពប្លុនត្រូវសង្កេតកត់ត្រានិងធ្វើប្រមាណវិធី
- កំណត់រយៈពេល 10នាទី
- ឱ្យសិស្សនិយាយឡើងវិញពីរបៀបពិភាក្សា
- ចែកក្រុមពិភាក្សាមាន ប្រធានក្រុម លេខាកត់ត្រា និងអ្នកបកស្រាយរួចឱ្យសិស្សចូលក្រុម
- ឱ្យប្រធានក្រុមឡើងយកសម្ភារៈ
- ឱ្យសិស្សចាប់ផ្តើមពិភាក្សាហើយគ្រូសរសេររយៈពេលលើក្តារខៀន
- ដើរសម្របសម្រួលតាមក្រុម

**សកម្មភាពទី៤៖ របាយការណ៍ក្រុម**


- ឱ្យសិស្សឡើងបិទរបាយការណ៍ក្រុម
- ឱ្យតំណាងក្រុមឡើងបកស្រាយលទ្ធផល និងឱ្យក្រុមដទៃសាកសួរបើមានចម្ងល់
- សម្របសម្រួលការបកស្រាយ
- សរសេរការបូកសរុបលើក្តារខៀន

**ការបូកសរុប**

$\frac{1}{5}+\frac{2}{5}=\square$

$\frac{1}{5}+\frac{2}{5}=\frac{1+2}{5}=\frac{3}{5}$

ដូចនេះ៖ $\frac{1}{5}+\frac{2}{5}=\frac{3}{5}$




**សកម្មភាពទី៥៖ផ្ទៀងផ្ទាត់ការប៉ាន់ស្មាន**

- ដឹកនាំសិស្សធ្វើការផ្ទៀងផ្ទាត់ការប៉ាន់ស្មានទៅនឹងការបូកសរុប
- លើកសរសើរសិស្សដែលប៉ាន់ស្មានបានត្រឹមត្រូវ

## ខ. វិធីដកប្រភាគ

បញ្ហាទី2៖ *ដើម្បីដកប្រភាគមានភាគបែងដូចគ្នាតើត្រូវធ្វើដូចម្តេច ?*

*ចូរកត់ផលដក* $\frac{6}{7}-\frac{3}{7}=\square$


**(យកលំនាំបង្រៀនដូចបញ្ហាទី១ដែរ)**

**ការបូកសរុប**

$\frac{6}{7}-\frac{3}{7}=\square$

$\frac{6}{7}-\frac{3}{7}=\frac{6-3}{7}=\frac{3}{7}$

ដូចនេះ $\frac{6}{7}-\frac{3}{7}=\frac{3}{7}$



**សកម្មភាពទី៦៖ ការកសាងបញ្ញត្តិ**

- សួរកពាក្យគន្លឹះ៖ តើមានពាក្យអ្វីខ្លះដែលជាពាក្យគន្លឹះទាក់ទងនឹងខ្លឹមសារមេរៀនយើងថ្ងៃនេះ។
- សរសេរពាក្យគន្លឹះដាក់លើក្តារខៀន (បូកប្រភាគ ដកប្រភាគ ភាគបែងដូចគ្នា រក្សាភាគបែង សម្រួល ភាគយក បូក ដក)
- ឱ្យសិស្សសាកល្បងកសាងបញ្ញត្តិតាមរយៈពាក្យគន្លឹះ(គ្រូជួយបំពេញបន្ថែមខ្លះៗ)
- សរសេរបញ្ញត្តិលើក្តារខៀនដោយឱ្យសិស្សអានតាមតៗគ្នារហូតសរសេរចប់

**បញ្ញត្តិ៖ ដើម្បីបូក ឬដកប្រភាគដែលមានភាគបែងដូចគ្នា យើងត្រូវបូក ឬដកភាគយកនឹងភាគយករីឯភាគបែងរក្សាទុកនៅដដែល។ បើផលបូក ឬផលដកនោះជាប្រភាគបង្រួមបានយើងត្រូវសម្រួលប្រភាគនោះឱ្យទៅជាប្រភាគបង្រួមមិនបាន។**

- ឱ្យសិស្សអានបញ្ញត្តិ
- សរសេរលំហាត់អនុវត្តលើបញ្ញត្តិដាក់លើក្តារខៀន $\frac{6}{12}+\frac{3}{12}=\frac{6+3}{12}=\frac{9}{12}=\frac{3}{4}$
- ឱ្យសិស្សពូកែឡើងធ្វើលើក្តារខៀនឯសិស្សដទៃធ្វើដាក់ក្តារឆ្នួន
- ពន្យល់បន្ថែមឱ្យសិស្សកាន់តែយល់ច្បាស់

**សកម្មភាពទី៧៖ ដាក់ចំណងជើងមេរៀន**

- សួរកចំណងជើងមេរៀន៖ តើមេរៀនថ្ងៃនេះមានចំណងជើងដូចម្តេច?
- សរសេរចំណងជើងមេរៀនលើក្តារខៀន(**វិធីបូកវិធីដកប្រភាគមានភាគបែងដូចគ្នា**)
- ឱ្យសិស្សអានមេរៀន
- ឱ្យសិស្សកត់មេរៀន

## ២.២. លំនាំនៃការបង្រៀនចរណីមាត្រ

**ផ្ទៃក្រឡាចតុកោណកែងនិងផ្ទៃក្រឡាការេ** (2ម៉ោង)

### ក. ផ្ទៃក្រឡាចតុកោណកែង

**សកម្មភាពទី១៖ ដាក់បញ្ហា**

- ទំនាក់ទំនង
- ដាក់បញ្ហាផ្ទាល់មាត់៖ *ដើម្បីរកផ្ទៃក្រឡាចតុកោណកែងតើត្រូវធ្វើដូចម្តេច? ចូរគណនាផ្ទៃក្រឡាចតុកោណកែងដែលមានទទឹង3cmនិងបណ្តោយ4cm។*
- សួរឡើងវិញ ពីបញ្ហាតើអ្នកគ្រូនិយាយដូចម្តេចអម្បាញ់មិញ?
- សរសេរឬបិទបញ្ហាលើក្តារខៀន
  បញ្ហា៖ *ដើម្បីរកផ្ទៃក្រឡាចតុកោណកែងតើត្រូវធ្វើដូចម្តេច? ចូរគណនាផ្ទៃក្រឡាចតុកោណកែងដែលមានទទឹង3cmនិងបណ្តោយ4cm។*
- សួរកវត្តុបំណងនៃបញ្ហា តើបញ្ហានេះចង់ឱ្យប្អូនធ្វើដូចម្តេច?(ប្រាប់ពីវិធីរកផ្ទៃក្រឡាចតុកោណកែង)
- កែតម្រូវចម្លើយ


**សកម្មភាពទី២៖ ប៉ាន់ស្មាន**

- ឱ្យសិស្សប៉ាន់ស្មាន

- កត់ត្រាចម្លើយប៉ាន់ស្មានលើក្តារខៀន (បណ្តោយ ×ទទឹង) , (បណ្តោយ - ទទឹង ) , ( បណ្តោយ + ទទឹង)
- តើចម្លើយប៉ាន់ស្មាននេះដឹងថាត្រឹមត្រូវឬនៅ?( នៅទេ) ដូចនេះ ដើម្បីឱ្យដឹងថាការប៉ាន់ស្មានរបស់យើងនេះខុសឬត្រូវតើត្រូវធ្វើដូចម្តេច?(ពិភាក្សាក្រុមស្រាវជ្រាវតាមរយៈរូបភាព)

**សកម្មភាពទី៣៖ ពិភាក្សាស្រាវជ្រាវ**

- គ្រូបង្ហាញសម្ភារៈ




ក្រដាសA3 , ហ្វឺត

- ណែនាំរបៀបពិភាក្សា៖ តាមរយៈរូបភាពប្អូនត្រូវ សង្កេត គូររូបបង្ហាញនិងតត់ត្រាលទ្ធផល
- កំណត់រយៈពេល 10 នាទី
- ឱ្យសិស្សនិយាយឡើងវិញពីរបៀបពិភាក្សា
- ចែកក្រុមពិភាក្សាមាន ប្រធានក្រុម លេខាកត់ត្រា និងអ្នកបកស្រាយ រួចឱ្យសិស្សចូលក្រុម
- ឱ្យប្រធានក្រុមឡើងយកសម្ភារៈ
- ឱ្យសិស្សចាប់ផ្តើមពិភាក្សាហើយគ្រូសរសេរយៈពេលលើក្តារខៀន
- ដើរសម្របសម្រួលតាមក្រុម

**សកម្មភាពទី៤៖ របាយការណ៍ក្រុម**

- ឱ្យសិស្សឡើងបិទរបាយការណ៍ក្រុម
- ឱ្យតំណាងក្រុមឡើងបកស្រាយលទ្ធផល និងឱ្យក្រុមដទៃសាកសួរបើមានចម្ងល់
- សម្របសម្រួលការបកស្រាយ
- ធ្វើការបូកសរុប
  - ក្នុងចតុកោណកែងរាប់ឃើញមាន12ក្រឡា
  - គេអាចគណនាផ្ទៃក្រឡាដោយយក បណ្តោយគុណនឹងទទឹង

    $3cm \times 4cm = 12cm^2$
  - ជាទូទៅបើaនិង bជារង្វាស់ជ្រុងហើយ A ជាផ្ទៃក្រឡាចតុកោណកែងនោះ
  - ផ្ទៃក្រឡាចតុកោណកែងកំណត់ដោយ $A = a \times b$

**សកម្មភាពទី៥៖ ផ្សៀងផ្ទាត់ការប៉ាន់ស្មាន**


- ដឹកនាំសិស្សផ្សៀងផ្ទាត់ការប៉ាន់ស្មាន
- លើកសរសើរសិស្សដែលប៉ាន់ស្មានបានត្រឹមត្រូវ

## ខ. ផ្ទៃក្រឡាការេ

បញ្ហាទី2៖ ដើម្បីរកផ្ទៃក្រឡាការេតើត្រូវធ្វើដូចម្តេច? ចូរគណនាផ្ទៃក្រឡាការេដែលមានជ្រុង3cm។

**(យកលំនាំបង្រៀនដូចបញ្ហាទី១ដែរ)**

**ការបូកសរុប**




- ការរោប់ឃើញមាន៩ក្រឡា
- គេអាចគណនាផ្ទៃក្រឡាការេដោយយកជ្រុងគុណនឹងជ្រុង

  $3cm \times 3cm = 9cm^2$
- បើaជាវង្វាស់ជ្រុងហើយ A ជាផ្ទៃក្រឡានៃការេនោះ
- ផ្ទៃក្រឡាការេកំណត់ដោយ $A = a \times a$

**សកម្មភាពទី៦៖ ការកសាងបញ្ញត្តិ**

សួរបញ្ជាក់៖

- តើaជាប្រវែងអ្វី? (ប្រវែងបណ្តោយ , វង្វាស់ជ្រុង)
- តើbជាប្រវែងអ្វី?(ប្រវែងទទឹង)
- តើផ្ទៃក្រឡាកំណត់ដោយអក្សរអ្វី?A
- សួររកពាក្យគន្លឹះដែលទាក់ទងនឹងខ្លឹមសារមេរៀន
- សរសេរពាក្យគន្លឹះដាក់លើក្តារខៀន (ផ្ទៃក្រឡាចតុកោណកែង ការេ ទទឹង បណ្តោយ គុណ ជ្រុង)
- ឱ្យសិស្សសាកល្បងកសាងបញ្ញត្តិតាមរយៈពាក្យគន្លឹះ(គ្រូជួយបំពេញបន្ថែមខ្លះៗ ឬប្រើសំណួរបំផុស)
- សរសេរបញ្ញត្តិលើក្តារខៀនដោយឱ្យសិស្សអានតាមតៗគ្នារហូតសរសេរចប់

**បញ្ញត្តិ៖**

**ផ្ទៃក្រឡាចតុកោណកែង = បណ្តោយ × ទទឹង**


**ឬ $A = a \times b$**


**ផ្ទៃក្រឡាការេ = ជ្រុង ×ជ្រុង**

**ឬ $A = a \times a$**

- ឱ្យសិស្សអានបញ្ញត្តិ
- បិទលំហាត់អនុវត្តបញ្ញត្តិលើក្តារខៀន

  ចូរកផ្ទៃក្រឡារូបខាងក្រោម



- ឱ្យសិស្សពូកែឡើងធ្វើលើក្តារខៀនឯសិស្សដទៃធ្វើដាក់ក្តារឆ្នួន
- ពន្យល់បន្ថែមឱ្យសិស្សកាន់តែយល់ច្បាស់

**សកម្មភាពទី៧ ៖ ដាក់ចំណងជើងមេរៀន**

- សួរកចំណងជើងមេរៀន តើមេរៀនថ្ងៃនេះមានចំណងជើងដូចម្តេច? (ផ្នែក្រឡាចតុកោណកែងនិងការ) ករណីសិស្សមិនអាចឆ្លើយបានគ្រូប្រាប់
- សរសេរចំណងជើងមេរៀនលើក្តារខៀន
- ឱ្យសិស្សអានមេរៀន

## ២.៣. ដំណាំនៃការបង្រៀនចំណោទ

ការបង្រៀនដោះស្រាយចំណោទ អាចប្រព្រឹត្តទៅតាមដំហានខាងក្រោម៖

- ឱ្យសិស្សយល់ប្រធាន
- ឱ្យសិស្សជ្រើសរើសប្រមាណវិធី
- ឱ្យសិស្សគណនាលទ្ធផល
- ឱ្យសិស្សធ្វើងផ្ទាត់លទ្ធផល

**សកម្មភាពទី១៖ ដាក់ប្រធានចំណោទ**

ឧទាហរណ៍៖ ក្រសួងកសិកម្មផ្តល់ស្រូវពូជទម្ងន់ 2 680kg ដល់កសិករ 320គ្រួសារ។ សាលាឃុំបន្ថែមស្រូវពូជទម្ងន់2 120kg ទៀត។

ក. តើស្រូវពូជទាំងអស់មានទម្ងន់ប៉ុន្មានគីឡូក្រាម?

ខ .តើគ្រួសារនីមួយៗទទួលស្រូវពូជបានប៉ុន្មានគីឡូក្រាម?

- អានប្រធានចំណោទឱ្យសិស្សស្តាប់
- ឱ្យសិស្សអានប្រធានចំណោទឱ្យបានច្រើននាក់

**សកម្មភាពទី២៖ ប៉ាន់ស្មាន**

- ឱ្យសិស្សប៉ាន់ស្មាន
- កត់ត្រាចម្លើយប៉ាន់ស្មានលើក្តារខៀន(ក= 4 800kg , ខ=15kg)
- តើចម្លើយប៉ាន់ស្មាននេះដឹងថាត្រឹមត្រូវ ឬនៅ?(នៅទេ)
- ដូចនេះដើម្បីឱ្យដឹងថាការប៉ាន់ស្មានរបស់យើងនេះខុសឬត្រូវ តើត្រូវធ្វើដូចម្តេច?(ពិភាក្សាក្រុម)

**សកម្មភាពទី៣៖ ពន្យល់ប្រធានចំណោទ**

- ណែនាំឱ្យសិស្សយល់ប្រធានចំណោទដោយចោទសំណួរបន្តបន្ទាប់៖
  - តើក្រសួងកសិកម្មផ្តល់ស្រូវពូជទម្ងន់ប៉ុន្មានគីឡូក្រាម?(2 680kg)
  - តើសាលាឃុំបន្ថែមស្រូវពូជប៉ុន្មានគីឡូក្រាម?(2 120kg)
  - តើគ្រួសារដែលត្រូវទទួលស្រូវពូជមានប៉ុន្មានគ្រួសារ?(320គ្រួសារ)
  - តើក្នុងប្រធានចំណោទគេសួរកអ្វី?(រកទម្ងន់ស្រូវពូជទាំងអស់ , រកទម្ងន់ស្រូវពូជដែលគ្រួសារនីមួយៗទទួលបាន)
  - ដើម្បីរកទម្ងន់ស្រូវពូជទាំងអស់តើត្រូវប្រើប្រមាណវិធីអ្វី?(ប្រមាណវិធីបូក)

- តើយកអ្វីបូកនឹងអ្វី?(2 680kg+2 120kg = ☐ )
- ដើម្បីរកទម្ងន់ស្រូវពូជដែលគ្រួសារនីមួយៗទទួលបានតើត្រូវប្រើប្រមាណវិធីអ្វី? (ប្រមាណវិធីចែក)
- តើយកអ្វីចែកនឹងអ្វី?(យកទម្ងន់ស្រូវទាំងអស់ចែកនឹងចំនួនគ្រួសារដែលត្រូវទទួល4800kg÷320 = ☐
- តើទម្ងន់ស្រូវទាំងអស់ដឹងហើយឬនៅ?(ដឹងហើយ)

○ ឱ្យសិស្សម្នាក់ឡើងសរសេរល្បះលេខលើក្តារខៀន (2 680kg + 2 120kg = ☐),
(4 800kg÷320 = ☐)

**សកម្មភាពទី៤៖ ពិភាក្សាក្រុម**

○ ណែនាំរបៀបពិភាក្សា តាមរយៈល្បះលេខ ចូរប្អូនធ្វើប្រមាណវិធីនិងរបៀបឆ្លើយ
○ កំណត់រយៈពេល10 នាទី
○ ឱ្យសិស្សនិយាយឡើងវិញពីរបៀបពិភាក្សា
○ ចែកក្រុមពិភាក្សាមាន ប្រធានក្រុម លេខាកត់ត្រា និងអ្នកបកស្រាយ រួចឱ្យសិស្សចូលក្រុម
○ ឱ្យសិស្សចូលក្រុម
○ ឱ្យសិស្សចាប់ផ្តើមពិភាក្សាហើយគ្រូសរសេររយៈពេលលើក្តារខៀន
○ ដើរសម្របសម្រួលតាមក្រុម

**សកម្មភាពទី៥៖ របាយការណ៍ក្រុម**

○ ឱ្យសិស្សឡើងបិទរបាយការណ៍ក្រុម
○ ឱ្យតំណាងក្រុមឡើងបកស្រាយលទ្ធផល និងឱ្យក្រុមដទៃសាកសួរបើមានចម្ងល់
○ សម្របសម្រួលការបកស្រាយ
○ សរសេរការបូកសរុបលើក្តារខៀន

**ការបូកសរុប**

ប្រមាណវិធី

$$\begin{array}{r} 2680 \\ +\ 2120 \\ \hline 4800 \end{array} \qquad \begin{array}{r|l} 4800 & 320 \\ \hline -\ 320 & 15 \\ \hline 1600 & \\ -\ 1600 & \\ \hline 0 & \end{array}$$

| កំណែ | របៀបឆ្លើយ |
|---|---|
| | រកទម្ងន់ស្រូវពូជទាំងអស់<br>2 680kg +2 120kg = 4 800kg<br>រកទម្ងន់ស្រូវដែលគ្រួសារនីមួយៗទទួលបាន<br>4 800kg ÷ 320 = 15kg<br>ឆ្លើយថា៖ ក. ស្រូវពូជទាំងអស់ទម្ងន់ . 4 800kg<br>ខ. គ្រួសារនីមួយៗទទួលបានស្រូវពូជទម្ងន់ 15kg |

**សកម្មភាពទី៦៖ ផ្ទៀងផ្ទាត់ការប៉ាន់ស្មាន**

- ដឹកនាំសិស្សផ្ទៀងផ្ទាត់លទ្ធផលទាំង 5ក្រុម
- លើកសរសើរក្រុមដែលធ្វើបានត្រឹមត្រូវ
- ឱ្យសិស្សអានរបៀបឆ្លើយឬចម្លើយ

**សកម្មភាពទី៧៖ កត់មេរៀន**

- ឱ្យសិស្សកត់ប្រធានចំណោទ ប្រមាណវិធី និងរបៀបឆ្លើយ

# ផ្នែកទី៣
# សណាកម៉្រតំពូកនិងមេរៀន

# ជំពូកទី១

# ចំនួន

| | |
|---|---|
| **រយៈពេល** | 9ម៉ | 
| **វត្ថុបំណងមេរៀន** | គណនាចំនួន ១000 000 ។ |
| **ចំណងជើងមេរៀន** | |
| **មេរៀនទី1** | អំណាន និងសំណេរចំនួនធំជាង ១000 000 |
| **មេរៀនទី2** | ការប្រៀបធៀបនិងរៀបលំដាប់ចំនួន |
| **មេរៀនទី3** | ខ្ទង់និងតម្លៃលេខតាមខ្ទង់ |
| **មេរៀនទី4** | ការបង្គត់ចំនួន |
| **មេរៀនទី5** | ការគណនាមធ្យមនព្វន្ត |
| **មេរៀនទី6** | លំហាត់សាឡើងវិញ |

| | |
|---|---|
| **មេរៀនទី1** | **អំណាន និងសំណេរចំនួនធំជាង ១000 000** |
| **រយៈពេល** | 1ម៉ |
| **វត្ថុបំណង** | អាននិងសរសេរចំនួនធំជាង១000 000 បានត្រឹមត្រូវ។ |
| **សម្ភារឧបទេស** | ស.ស. ទំព័រទី 02 ដល់ទំព័រទី 03<br>រូបភាពនៅទំព័រទី02<br>ប័ណ្ណលេខ 2 325 022 , 874 465 250 |
| **ដំណើរការបង្រៀន** | មើលលំនាំនៃការបង្រៀនទំព័រ11 |
| **ចម្លើយ/កំណែលំហាត់** | ទី1៖<br>ក. 125 243 102<br>សរសេរតាមខ្ទង់គឺ: មួយរយម្ភៃប្រាំលាន ពីរសែនបួនម៉ឺនបីពាន់មួយរយពីរ។<br>សរសេរតាមថ្នាក់គឺ: មួយរយម្ភៃប្រាំលាន ពីររយសែសិបបីពាន់ មួយរយពីរ។<br>ខ. 248 180 035<br>សរសេរតាមខ្ទង់គឺ: ពីររយសែសិបប្រាំបីលាន មួយសែនប្រាំបីម៉ឺនសាមសិបប្រាំ។<br>សរសេរតាមថ្នាក់គឺ: ពីររយសែសិបប្រាំបីលាន មួយរយប៉ែតសិបពាន់ សាមសិបប្រាំ។<br>គ. 405 276 930<br>សរសេរតាមខ្ទង់គឺ: បួនរយប្រាំលាន ពីរសែនប្រាំពីរម៉ឺនប្រាំមួយពាន់ប្រាំបួនរយសាមសិប។ |

| | |
|---|---|
| | សរសេរតាមថ្នាក់គឺ: បួនរយប្រាំលាន ពីររយចិតសិបប្រាំមួយពាន់ ប្រាំបួនរយសាមសិប។<br>ឃ. 2 871 135 463<br>សរសេរតាមខ្ទង់គឺ: ពីពាន់ប្រាំបីរយចិតសិបមួយលាន មួយសែនបីម៉ឺនប្រាំពាន់បួនរយ ហុកសិបបី។<br>សរសេរតាមថ្នាក់គឺ: ពីរពាន់ប្រាំបីរយចិតសិបមួយលាន មួយរយសាមសិបប្រាំពាន់ បួនរយ ហុកសិបបី។<br>ង. 4 376 718 360<br>សរសេរតាមខ្ទង់គឺ: បួនពាន់បីរយចិតសិបប្រាំមួយលាន ប្រាំពីរសែនមួយម៉ឺនប្រាំបី ពាន់បីរយហុកសិប។<br>សរសេរតាមថ្នាក់គឺ: បួនពាន់បីរយចិតសិបប្រាំមួយលាន ប្រាំពីររយដប់ប្រាំបីពាន់ បីរយ ហុកសិប។<br>ច. 6 053 871 189<br>សរសេរតាមខ្ទង់គឺ: ប្រាំមួយពាន់ហាសិបបីលាន ប្រាំបីសែនប្រាំពីរម៉ឺនមួយពាន់មួយរយ ប៉ែតសិបប្រាំបួន។<br>សរសេរតាមថ្នាក់គឺ: ប្រាំមួយពាន់ហាសិបបីលាន ប្រាំបីរយចិតសិបមួយពាន់ មួយរយ ប៉ែតសិបប្រាំបួន។<br>ទី2៖ ក. 385 250 035 ខ. 550 387 607<br>ទី3៖ ក. បីលាន ពីរយហាសិបប្រាំមួយពាន់ ប្រាំបីរយចិតសិបប្រាំ<br>ខ. បួនលាន ប្រាំបីរយដប់បីពាន់ ប្រាំពីររយម្ភៃប្រាំ<br>គ. ប្រាំលាន ប្រាំបួនរយម្ភៃពាន់ មួយរយម្ភៃបួន<br>ឃ. ប្រាំបួនលាន ប្រាំបីរយប្រាំពីរពាន់ប្រាំ<br>ង. ដប់ពីរលាន បីរយម្ភៃបួនពាន់ បួនរយដប់ពីរ<br>ច. ម្ភៃបួនលាន ប្រាំពីររយហាសិបប្រាំបីពាន់ ប្រាំមួយរយ<br>ឆ. ប៉ែតសិបពីរលាន ប្រាំពីររយម្ភៃបួនពាន់ ប្រាំរយបួន<br>ជ. 7 320 126 ឈ. 4 680 048 ញ. 10 435 656 ដ. 11 437 656<br>ឋ. 12 724 000 |

| **មេរៀនទី2** | **ការប្រៀបធៀបនិងរៀបលំដាប់ចំនួន** |
|---|---|
| **រយៈពេល** | 1ម៉ោ |
| **វត្ថុបំណង** | ប្រៀបធៀបនិងរៀបលំដាប់ចំនួនបានត្រឹមត្រូវ។ |
| **សម្ភារឧបទេស** | ស.ស. ទំព័រទី04ដល់ទំព័រទី05<br>ប័ណ្ណលេខ 3256401 និង 3257250 |

| | |
|---|---|
| **ជំណើរការបង្រៀន** | មើលលំនាំនៃការបង្រៀនទំព័រ11 |
| **ចម្លើយ/កំណែលំហាត់** | ទី1៖ ក. 3 251 820 > 426 875 ខ. 6 672 183 < 6 672 190<br>គ. 7 012 345 = 7 012 345 ឃ. 9 782 608 < 9 783 680<br>ង. 5 420 350 > 4 520 265 ច. 7 963 250 > 7 959 870<br>ឆ. 6 435 601 = 6 435 601 ជ. 4 652 108 < 4 653 280<br>ទី2៖ ក. ពីតូចទៅធំ៖ 5 648 310 ; 5 648 402 ; 5 648 837 ; 6 548 301<br>ពីធំទៅតូច៖ 6 548 301 ; 5 648 837 ; 5 648 402 ; 5 648 310<br>ខ. ពីតូចទៅធំ៖ 3 003 003 ; 3 300 033 ; 3 300 303 ; 3 303 003<br>ពីធំទៅតូច៖ 3 303 003 ; 3 300 303 ; 3 300 033 ; 3 003 003<br>ទី3៖ ក. ចំនួនដែលធំជាងគេបំផុតគឺ 8 979 191<br>ចំនួនដែលតូចជាងគេបំផុតគឺ 8 907 969<br>ខ. ចំនួនដែលធំជាងគេបំផុតគឺ 6 199 015<br>ចំនួនដែលតូចជាងគេបំផុតគឺ 6 197 969<br>គ. ចំនួនដែលធំជាងគេបំផុតគឺ 7 205 242<br>ចំនួនដែលតូចជាងគេបំផុតគឺ 7 204 872<br>ឃ. ចំនួនដែលធំជាងគេបំផុតគឺ 9 859 070<br>ចំនួនដែលតូចជាងគេបំផុតគឺ 9 849 897 |

| | |
|---|---|
| **មេរៀនទី3** | **ខ្ទង់និងតម្លៃលេខតាមខ្ទង់** |
| **រយៈពេល** | 1ម៉ោ |
| **វត្ថុបំណង** | ប្រាប់ខ្ទង់និងតម្លៃលេខតាមខ្ទង់បានត្រឹមត្រូវ។ |
| **សម្ភារឧបទេស** | ស.ស. ទំព័រទី06ដល់ទំព័រទី07<br>រូបភាពនៅទំព័រទី 06<br>ប័ណ្ណលេខ 3 024 103 … |
| **ជំណើរការបង្រៀន** | មើលលំនាំនៃការបង្រៀនទំព័រ11 |
| **ចម្លើយ/កំណែលំហាត់** | ទី1៖ ក. 80 × 1 000 000 ខ. 0 × 1000 គ. 5 × 10 000<br>ទី2៖ ក. 15 000 000 + 700 000 + 20 000 + 1 000 + 500 + 40<br>ខ. 281 000 000 + 200 000 + 100 + 80 + 3<br>គ. 308 000 000 + 5 000 + 300 + 50<br>ទី3៖ ក. 4 500 000 + 305 000 + 0 + 10 + 7 = 4 805 017<br>ខ. 50 000 000 + 0 + 0 + 200 + 500 + 0 + 8 = 50 000 708<br>គ. 15 000 000 + 400 000 + 30 000 + 0 + 20 + 5 = 15 430 025 |

ទី4៖

| លាន | សែន | ម៉ឺន | ពាន់ | រយ | ដប់ | រាយ |
|---|---|---|---|---|---|---|
| 4 | 8 | 0 | 5 | 0 | 1 | 7 |
| 50 | 0 | 0 | 0 | 7 | 0 | 8 |
| 15 | 4 | 3 | 0 | 0 | 2 | 5 |

ទី5៖ ក. 2 000 000 + 0 + 40 000 + 0 + 300 + 10 + 2

ខ. 35 000 000 + 0 + 0 + 400 000 + 500

គ. 10 000 000 + 300 000 + 50 000 + 2 000 + 100 + 40 + 3

ទី6៖ ចំនួនតូចបំផុតគឺ 0 123 578 , ចំនួនធំបំផុតគឺ 8 753 210

| **មេរៀនទី4** | **ការបង្គត់ចំនួន** |
|---|---|
| **រយៈពេល** | 1ម៉ោ |
| **វត្ថុបំណង** | បង្គត់ចំនួនបានត្រឹមត្រូវ។ |
| **សម្ភារឧបទេស** | ស.ស. ទំព័រទី08ដល់ទំព័រទី09<br>រូបភាពនៅទំព័រទី 08<br>ប័ណ្ណលេខ 2 782 150 ; 5 623 501 ; 4 567 304 … |
| **ដំណើរការបង្រៀន** | មើលលំនាំនៃការបង្រៀនទំព័រ11 |
| **ចម្លើយ/កំណែលំហាត់** | ទី1៖ ក. 2 000 000 ខ. 7 000 000 គ. 9 000 000 ឃ. 2 000 000 ង. 6 000 000<br>ច. 7 000 000 ឆ. 10 000 000 ជ. 8 000 000 ឈ. 9 000 000<br>ទី2៖ ក. 570 000 ខ. 460 000 គ. 760 000 ឃ. 200 000 ង. 810 000<br>ច. 930 000 ឆ. 620 000 ជ. 470 000 ឈ. 200 000<br>ទី3៖ ក. 7 800 000 ខ. 11 400 000 គ. 23 200 000 ឃ. 18 100 000<br>ង. 37 100 000 ច. 40 400 000 ឆ. 9 000 000 ជ. 6 300 000 ឈ. 4 300 000<br>ទី4៖ 13 000 000 នាក់<br>ទី5៖ 590 000 តោន |

| **មេរៀនទី5** | **ការគណនាមធ្យមនព្វន្ត** |
|---|---|
| **រយៈពេល** | 1ម៉ោ |
| **វត្ថុបំណង** | គណនាមធ្យមនព្វន្តបានត្រឹមត្រូវ។ |
| **សម្ភារឧបទេស** | ស.ស. ទំព័រទី10ដល់ទំព័រទី10<br>រូបភាពនៅទំព័រទី10<br>ប័ណ្ណលេខ 20 ; 15 ; 17 ; 7 ; 10 ; 11 ; 18 ; … |

| | |
|---|---|
| **ដំណើរការបង្រៀន** | មើលលំនាំនៃការបង្រៀនទំព័រ11 |
| **ចម្លើយ/កំណែលំហាត់** | **លំហាត់៖**<br>ក. 40 ខ. 680 គ. 91 ឃ. 248<br>**ចំណោទ៖**<br>ទី1៖ 1400 ៛ , ទី2៖ 7.65 , ទី3៖ 47 គ្រឿង |

| | |
|---|---|
| **មេរៀនទី6** | **លំហាត់សាឡើងវិញ** |
| **រយៈពេល** | 1ម៉ោ |
| **វត្ថុបំណង** | ធ្វើលំហាត់សាឡើងវិញបានត្រឹមត្រូវ។ |
| **សម្ភារឧបទេស** | ស.ស. ទំព័រទី11<br>ប័ណ្ណលេខ ទំព័រទី11 |
| **ចម្លើយ/កំណែលំហាត់** | ទី1៖<br>ក. 13 540 321<br>សរសេរតាមថ្នាក់គឺ ដប់បីលាន ប្រាំរយសែសិបពាន់ បីរយម្ភៃមួយ<br>សរសេរតាមខ្នង់គឺ ដប់បីលាន ប្រាំសែនបួនម៉ឺនបីរយម្ភៃមួយ<br>ខ. 25 180 035<br>សរសេរតាមថ្នាក់គឺ ម្ភៃប្រាំលាន មួយរយប៉ែតសិបពាន់ សាមសិបប្រាំ<br>សរសេរតាមខ្នង់គឺ ម្ភៃប្រាំលាន មួយសែនប្រាំបីម៉ឺនសាមសិបប្រាំ<br>គ. 505 276 930<br>សរសេរតាមថ្នាក់គឺ ប្រាំរយប្រាំលាន ពីររយចិតសិបប្រាំមួយពាន់ ប្រាំបួនរយសាមសិប<br>សរសេរតាមខ្នង់គឺ៖ ប្រាំរយប្រាំលាន ពីរសែនប្រាំពីរម៉ឺនប្រាំមួយពាន់ប្រាំបួនរយសាមសិប<br>ឃ. 2 917 135 463<br>សរសេរតាមថ្នាក់គឺ ពីរពាន់ប្រាំបួនរយដប់ប្រាំពីរលាន មួយរយសាមសិបប្រាំពាន់<br>បួនរយហុកសិបបី<br>សរសេរតាមខ្នង់គឺ ពីរពាន់ប្រាំបួនរយដប់ប្រាំពីរលាន មួយសែនបីម៉ឺនប្រាំពាន់បួនរយ<br>ហុកសិបបី<br>ង. 4 567 718 630<br>សរសេរតាមថ្នាក់គឺ បួនពាន់ប្រាំរយហុកសិបប្រាំពីរលាន ប្រាំពីររយដប់ប្រាំបីពាន់ ប្រាំមួយ<br>រយសាមសិប<br>សរសេរតាមខ្នង់គឺ បួនពាន់ប្រាំរយហុកសិបប្រាំពីរលាន ប្រាំពីរសែនមួយម៉ឺនប្រាំបីពាន់<br>ប្រាំមួយរយសាមសិប<br>ច. 5 063 871 189<br>សរសេរតាមថ្នាក់គឺ ប្រាំពាន់ហុកសិបបីលាន ប្រាំបីរយចិតសិបមួយពាន់ មួយរយប៉ែត |

សិបប្រាំបួន

សរសេរតាមខ្នង់គឺ ប្រាំពាន់ហុកសិបបីលាន ប្រាំបីសែនប្រាំពីរម៉ឺនមួយពាន់ មួយរយប៉ែត

សិបប្រាំបួន

ទី2៖ ក. 281 223 050 ខ. 455 020 035 គ. 250 000 035

ទី3៖ ក. ពីធំទៅតូច៖ 3 050 295 ; 2 920 571 ; 2 883 395 ; 2 639 505

ខ. ពីតូចទៅធំ៖ 363 985 ; 3 810 571 ; 3 835 295 ; 3 838 504

ទី4៖ ក. 72 000 000 + 100 000 + 50 000 + 1 000 + 400 + 50

ខ. 182 000 000 + 300 000 + 10 000 + 300 + 80 + 1

គ. 538 000 000 + 2 000 + 500 + 30

ទី5៖ ក. 25 005 402 ខ. 405 002 005 គ. 550 000 318

ទី6៖ ក. ត្រឹមខ្នង់លាន៖ 5 000 000 ; 7 000 000 ; 7 000 000

ខ. ត្រឹមខ្នង់ម៉ឺន៖ 55 840 000 ; 70 960 000 ; 55 220 000

# ជំពូកទី២

# វិធីគុណ វិធីចែក

| | |
|---|---|
| **រយៈពេល** | 24ម៉ោ |
| **វត្ថុបំណងមេរៀន** | គុណនិងចែកចំនួនបានត្រឹមត្រូវ ។ |
| **ចំណងជើងមេរៀន** | |
| **មេរៀនទី1** | ការគុណចំនួនមានលេខ4ខ្ទង់នឹង2ខ្ទង់ |
| **មេរៀនទី2** | ការគុណចំនួនមានលេខ4ខ្ទង់នឹង3ខ្ទង់ |
| **មេរៀនទី3** | ការដោះស្រាយចំណោទដោយប្រើអង្កត់ចំនួន |
| **មេរៀនទី4** | លំហាត់សាឡើងវិញ |
| **មេរៀនទី5** | ការចែកចំនួនមានលេខ4ខ្ទង់នឹង3ខ្ទង់គ្មានសំណល់ |
| **មេរៀនទី6** | ការចែកចំនួនមានលេខ4ខ្ទង់នឹង3ខ្ទង់មានសំណល់ |
| **មេរៀនទី7** | ការចែកដែលផលចែកជាចំនួនទសភាគ |
| **មេរៀនទី8** | ការចែកដែលតំណាំងចែកនិងតួចែកមានលេខសូន្យនៅខាងចុង |
| **មេរៀនទី9** | លំហាត់សាឡើងវិញ |
| **មេរៀនទី10** | ចំណោទ |

| | |
|---|---|
| **មេរៀនទី1** | **ការគុណចំនួនមានលេខ4ខ្ទង់នឹង2ខ្ទង់** |
| **រយៈពេល** | 2ម៉ោ |
| **វត្ថុបំណង** | គុណចំនួនមានលេខ4ខ្ទង់នឹង2ខ្ទង់បានត្រឹមត្រូវ។ |
| **សម្ភារឧបទេស** | ស.ស. ទំព័រទី13ដល់ទំព័រទី14<br>រូបភាពនៅទំព័រទី13 |
| **ដំណើរការបង្រៀន** | មើលលំនាំនៃការបង្រៀនទំព័រ11 |
| **ចម្លើយ/កំណែលំហាត់** | **លំហាត់៖**<br>ទី1៖ ក. 30 520 ខ. 55 315 គ. 100 660 ឃ. 148 176 ង. 162 360 ច. 206 330<br>ឆ. 271 674 ជ. 376 536 ឈ. 466 515 ញ. 524 745 ដ. 565 992 ឋ. 614 460<br>ឌ. 628 680 ឍ. 680 480 ណ. 869 876<br>ទី2៖ ក. 12 000 ខ. 50 000 គ. 150 000 ឃ. 15 200 ង. 200 000 ច. 201 000<br>ឆ. 240 000 ជ. 48 400 ឈ. 110 110 |

ទី3៖

| | | | | | |
|---|---|---|---|---|---|
| តួគុណទី១ | 2 50 | 3 685 | 4 205 | 6 084 | 7 849 |
| តួគុណទី២ | 28 | 36 | 48 | 67 | 85 |
| ផលគុណ | 70 000 | 132 660 | 20 840 | 407 628 | 667 167 |

**ចំណោទ៖**

ទី1៖ 113 600វ

ទី2៖ 327 600វ

ទី3៖ ក. 108 400វ ខ. 24 400វ

ទី4៖ បង្កើតចំណោទតាមល្បះដែលឱ្យ

| | |
|---|---|
| **មេរៀនទី2** | **ការគុណចំនួនមានលេខ4ខ្ទង់នឹង3ខ្ទង់** |
| **រយៈពេល** | 1ម៉ |
| **វត្ថុបំណង** | គុណចំនួនមានលេខ4ខ្ទង់នឹង3ខ្ទង់បានត្រឹមត្រូវ។ |
| **សម្ភារឧបទេស** | ស.ស. ទំព័រទី15 ដល់ទំព័រទី16<br>រូបភាពនៅទំព័រទី15 |
| **ដំណើរការបង្រៀន** | មើលលំនាំនៃការបង្រៀនទំព័រ11 |
| **ចម្លើយ/កំណែលំហាត់** | **លំហាត់៖**<br>ទី1៖ ក. 178 200 ខ. 338 688 គ. 528 162 ឃ. 791 252 ង. 1 184 994<br>ច. 1 638 840 ឆ. 2 028 048 ជ. 2 880 374 ឈ. 4 091 871 ញ. 4 104 000<br>ដ. 4 451 697 ឋ. 5 125 920<br>ទី2៖ ក. 900 000 ខ. 1 000 000 គ. 3 000 000<br>ទី3៖ |

| | | | | | | |
|---|---|---|---|---|---|---|
| ក. | 20 | 60 | 180 | 540 | 1 620 | 4 860 |
| ខ. | 5 | 40 | 320 | 2 560 | 20 480 | 163 840 |

**ចំណោទ៖**

ទី1៖ 187 500Kg

ទី2៖ 4 125 000សម្រាប់

ទី3៖ 543 750វ

ទី4៖ 2 700 000ល

ទី5៖ ក. 794 000វ ខ. 740 000វ

| | |
|---|---|
| **មេរៀនទី3** | **ដោះស្រាយចំណោទដោយប្រើអង្កត់** |

| | |
|---|---|
| **រយៈពេល** | 2ម៉ោ |
| **វត្ថុបំណង** | ដោះស្រាយចំណោទដោយប្រើអង្កត់បានត្រឹមត្រូវ។ |
| **សម្ភារឧបទេស** | ស.ស. ទំព័រទី17 ដល់ទំព័រទី19<br>រូបភាពនៅទំព័រទី17-18 |
| **ដំណើរការបង្រៀន** | មើលលំនាំនៃការបង្រៀនទំព័រ16-18 |
| **ចម្លើយ/ចំណោទ** | ទី1៖ ចំនួនសិស្សស្រីគឺ 1 254ន , ចំនួនសិស្សប្រុសគឺ 1 306ន<br>ទី2៖ 2 295kg<br>ទី3៖ 3 450 000៛<br>ទី4៖ កូនទី១បានប្រាក់ 7000៛ , កូនទី២បានប្រាក់ 1 4000៛ , កូនទី៣បានប្រាក់ 21 000៛ |

| | |
|---|---|
| **មេរៀនទី4** | **លំហាត់សាឡើងវិញ** |
| **រយៈពេល** | 1ម៉ោ |
| **វត្ថុបំណង** | គុណលេខបានត្រឹមត្រូវ។ |
| **សម្ភារឧបទេស** | ស.ស. ទំព័រទី19ដល់ទំព័រទី20 |
| **ចម្លើយ/កំណែលំហាត់** | **លំហាត់៖**<br>ទី1៖ ក. 63 700 ខ. 202 130 គ. 339 100 ឃ. 154 125 ង. 687 800<br>ច. 546 300ឆ. 859 342 ជ. 655 250 ឈ. 579 375 ញ. 1 390 925<br>ដ. 2 397 720 ឋ. 1 647 175<br>ទី2៖ |

| × | 3 400 | 3865 | 7 084 | 7 804 | 8 749 |
|---|---|---|---|---|---|
| 38 | 129 200 | 146 870 | 269 192 | 296 552 | 332 462 |
| 45 | 153 000 | 173 925 | 318 780 | 351 180 | 393 705 |
| 406 | 1 380 400 | 1 569 90 | 2 876 104 | 3 168 424 | 3 552 094 |
| 576 | 1 958 400 | 2 226 240 | 4 080 384 | 4 495 104 | 5 039 24 |

ទី3៖ ក. 2 000 000 ខ. 50 000 គ. 1 950 000

ទី4៖

| ល.រ. | ឈ្មោះទំនិញ | ចំនួន | តម្លៃរាយ | តម្លៃសរុប |
|---|---|---|---|---|
| 1 | ស៊ីម៉ងត៍ | 3បាវ | 13 500រៀល | 40 500៛ |
| 2 | កំបោរស | 30kg | 300រៀល | 9 000៛ |
| 3 | សង្កសី | 36បន្ទះ | 11 000រៀល | 396 000៛ |

| | | | | |
|---|---|---|---|---|
| 4 | តង្ហៀរ | 4កែស | 20 900រៀល | 83 600៛ |
| 5 | ដៃកគោល | 2កញ្ចប់ | 15 300រៀល | 30 600៛ |
| 6 | ដីខ្សាច់ | 3រ៉ឺម៉ក | 7 000រៀល | 21 000៛ |
| | | | តម្លៃសរុប | 580 700៛ |

**ចំណោទ៖**

ទី1៖ 2 364 600៛

ទី2៖ 5 396 000៛

ទី3៖ កន្លះបរិមាត្រ 6 000m ÷ 2 = 3 000m

ក. ប្រវែងទទឹង (3 000 – 540) ÷ 2 = 1 230m

ខ. ប្រវែងបណ្តោយ 1 230m + 540 = 1 770m

គ. ផ្ទៃក្រឡាចម្ការ 1 230m × 1 770m = 2 177 100$m^2$

| | |
|---|---|
| **មេរៀនទី5** | **ការចែកចំនួនមានលេខ 4ខ្ទង់នឹង 3ខ្ទង់គ្មានសំណល់** |
| **រយៈពេល** | 2ម៉ |
| **វត្ថុបំណង** | ចែកចំនួនមានលេខ 4ខ្ទង់នឹង **3**ខ្ទង់គ្មានសំណល់បានត្រឹមត្រូវ |
| **សម្ភារឧបទេស** | ស.ស. ទំព័រទី22ដល់ទំព័រ23<br>រូបភាពនៅទំព័រទី21 |
| **ដំណើរការបង្រៀន** | មើលលំនាំនៃការបង្រៀនទំព័រ11 |
| **ចម្លើយ/កំណែលំហាត់** | **លំហាត់៖**<br>ទី1៖ ក. 31 ខ. 7 គ. 8 ឃ. 35 ង. 43 ច. 38 ឆ. 8 ជ. 43 ឈ. 32 ញ. 17 ដ. 16 ឋ. 25 ឌ. 44 ឍ. 52 ណ. 9 ត. 16 ថ. 14 ទ. 27<br>ទី2៖ ក. 502 ខ. 8 554 គ. 1 284 ឃ. 154 ង. 6750 ច. 9450<br>ទី3៖ ក. 21 ខ. 17 គ. 9 ឃ. 20<br>ទី4៖ ក. 30 ខ. 30 គ. 25<br>**ចំណោទ៖**<br>ទី1៖ 70m<br>ទី2៖ ក. 550៛ ខ. 13 750៛<br>ទី3៖ ក. 13ដង ខ. 195បាវ<br>ទី4៖ ក. 4 800kg ខ. 15kg<br>ទី5៖ 8 លើក 120ធុង<br>ទី6៖ សិស្សបង្កើតចំណោទដោយឈ្មោះលេខដែលជាក់ឱ្យ |



| | |
|---|---|
| **មេរៀនទី6** | **ការចែកចំនួនមានលេខ 4ខ្ទង់នឹង 3ខ្ទង់មានសំណល់** |
| **រយៈពេល** | 2ម៉ |
| **វត្ថុបំណង** | ចែកចំនួនមានលេខ 4ខ្ទង់នឹង **3**ខ្ទង់មានសំណល់បានត្រឹមត្រូវ។ |
| **សម្ភារឧបទេស** | ស.ស. ទំព័រទី23<br>រូបភាពនៅទំព័រទី23 |
| **ដំណើរការបង្រៀន** | មើលលំនាំនៃការបង្រៀនទំព័រទី11 |
| **ចម្លើយ/កំណែលំហាត់** | **លំហាត់៖**<br>ទី1៖ ក. 19 សំណល់ 65 ខ. 15 សំណល់ 71 គ. 17 សំណល់ 59<br>ឃ. 12 សំណល់ 312 ង. 13 សំណល់ 49 ច. 8 សំណល់ 243<br>ឆ. 9 សំណល់ 64 ជ. 9 សំណល់ 239 ឈ. 10 សំណល់ 287<br>ញ. 10 សំណល់ 507 ដ. 9 សំណល់ 526 ឋ. 12 សំណល់ 97<br>ឌ. 12 សំណល់ 381 ឍ. 12 សំណល់ 159 ណ. 9 សំណល់ 441<br>ទី2៖ ក. 20 សំណល់ 122 ខ. 3 143 គ. 241 ឃ. 2 346<br>ទី3៖ ក. 5 ខ. 8 គ. 7<br>**ចំណោទ៖**<br>ទី1៖ 15kg នៅសល់អង្ករ 120kg<br>ទី2៖ ក. 10 រថយន្ត ខ. 45បាវ<br>ទី3៖ 31បាវ នៅសល់សណ្តែក 13kg<br>ទី4៖ ក. (680 + (680 – 30)) ÷ 300 = 4ក្បាល , ខ. 130ក្បាល<br>ទី5៖ ក. 7ក្បាល , ខ. 12ដើម , គ. 100៖<br>ទី6៖ សិស្សបង្កើតចំណោទតាមល្បះដៃលឱ្យ |

| | |
|---|---|
| **មេរៀនទី7** | **ការចែកដៃលផលចែកជាចំនួនទសភាគ** |
| **រយៈពេល** | 2ម៉ |
| **វត្ថុបំណង** | ចែកដៃលផលចែកជាចំនួនទសភាគបានត្រឹមត្រូវ។ |
| **សម្ភារឧបទេស** | ស.ស. ទំព័រទី26 ដល់ទំព័រទី27<br>រូបភាពនៅទំព័រទី26 |
| **ដំណើរការបង្រៀន** | មើលលំនាំនៃការបង្រៀនទំព័រ11 |
| **ចម្លើយ/កំណែលំហាត់** | **លំហាត់៖**<br>ទី1៖ ក. 205.5 ខ. 2.25 គ. 296.48 ឃ. 27.413<br>ទី2៖ ក. 14.2 ខ. 13.5 គ. 12.5 ឃ. 15.5 ង. 16.30 ច. 24.46 ឆ. 15.44 ជ. 18.44<br>ឈ. 50.2 ញ. 65.25 ដ. 60.625 ឋ. 47.91 ឌ. 83.33 ឍ. 80.83 ណ. 129.14 |

| | |
|---|---|
| | **ចំណោទ៖**<br>ទី1៖ 56.25km<br>ទី2៖ ក. 180km ខ. 185km គ. 30.83km<br>ទី3៖ ក. 10kg ខ. 2 500៛<br>ទី4៖ ក. 1.5kg ខ. 12 000៛<br>ទី5៖ ក. 30kg ខ. 1 967.08៛<br>ទី6៖ សិស្សបង្កើតចំណោទតាមល្បះលេខដែលឱ្យ |

| **មេរៀនទី8** | **ការចែកដែលតំណាំងចែកមានលេខ0នៅខាងចុង** |
|---|---|
| **រយៈពេល** | 2ម៉ |
| **វត្ថុបំណង** | ចែកដែលតំណាំងចែកមានលេខ0នៅខាងចុងបានត្រឹមត្រូវ។ |
| **សម្ភារឧបទេស** | ស.ស. ទំព័រទី28ដល់ទំព័រទី29<br>រូបភាពនៅទំព័រទី28 |
| **ដំណើរការបង្រៀន** | មើលលំនាំនៃការបង្រៀនទំព័រ11 |
| **ចម្លើយ/កំណែលំហាត់** | **លំហាត់៖**<br>ក. 4 ខ. 9 គ. 8 ឃ. 20 ង. 90 ច. 70 ឆ. 17 ជ. 23 ឈ. 64 ញ. 42 ដ. 25.5<br>ឋ. 36.25 ឌ. 200 ឍ. 17.06 ណ. 14.72 ត. 50 ថ. 29.73 ទ. 17.65<br>**ចំណោទ៖**<br>ទី1៖ ក. 650 ៛ ខ. 65 ក្ប<br>ទី2៖ 13 សន្លឹក<br>ទី3៖ ក. 51 គ្រឿង ខ. 34 គ្រឿង<br>ទី4៖ ក. 2 300៛ ខ. 5កញ្ចប់ គ. 4កញ្ចប់ ឃ. 2ដប<br>ទី5៖ រកផ្ទៃក្រឡាផ្ទៃសំណាក់ទាំងអស 32m × 10m = 320m$^2$<br>រកផ្ទៃក្រឡាផ្លូវដើរកណ្តាល 1.2m × 32m = 38.4m$^2$<br>រកផ្ទៃក្រឡាដែលត្រូវរៀបបន្ទប់ 320m$^2$ – 38.4m$^2$ = 281.6m$^2$<br>រកផ្ទៃក្រឡាបន្ទប់នីមួយៗ 4m × 4.4m = 17.6m$^2$<br>រកចំនួនបន្ទប់ទាំងអស់ 281.6 ÷ 17.6 = 16បន្ទប់<br>ទី6៖ សិស្សបង្កើតចំណោទតាមល្បះដែលឱ្យ |

| **មេរៀនទី9** | **លំហាត់សាឡើងវិញ** |
|---|---|
| **រយៈពេល** | 2ម៉ |
| **វត្ថុបំណង** | ចែកលេខបានត្រឹមត្រូវ។ |

| | |
|---|---|
| **សម្ភារឧបទេស** | ស.ស. ទំព័រទី29 ដល់ទំព័រទី30<br>រូបភាពនៅទំព័រទី29-30 |
| **ចម្លើយ/កំណែលំហាត់** | ទី1៖ ក. 42 ខ. 24.22 គ. 6.75 ឃ. 50 ង. 31 ច. 22.58 ឆ. 24.12 ជ. 52.64<br>ឈ. 31.71 ញ. 22.63 ដ. 15.49 ឋ. 13.31<br>ទី2៖<br><br>ទី3៖<br> |





| | |
|---|---|
| **មេរៀនទី10** | **ចំណោទ** |
| **រយៈពេល** | 2ម៉ោ |
| **វត្ថុបំណង** | ដោះស្រាយចំណោទបានត្រឹមត្រូវ។ |
| **សម្ភារឧបទេស** | ស.ស. ទំព័រទី32 |
| **ដំណើរការបង្រៀន** | មើលលំនាំនៃការបង្រៀនទំព័រទី16-18 |
| **ចម្លើយ/កំណែលំហាត់** | ទី1៖ ក. 2 000kg ខ. 80kg គ. 796 000វ |

ទី2៖ រកក្រឡាផ្ទៃដីនោះ

$150m \times 85m = 12\ 750m^2$

រកចំនួនប្រាក់ដែលលក់ដីនោះ

$12\ 750 \times 2\$ = 25\ 500\$$

រកចំនួនប្រាក់ទិញម៉ូតូប្រភេទទី១

$25\ 500\ \$ \times \frac{1}{2} = 12\ 750\$$

ក. ចំនួនប្រភេទម៉ូតូនីមួយៗដែលពូព្រីងទិញបាន

- ចំនួនម៉ូតូប្រភេទទី១

$12\ 750 \div 750 = 17$គ្រឿង

- ចំនួនម៉ូតូប្រភេទទី២

$12\ 750 \div 1\ 275 = 10$គ្រឿង

ខ. ប្រាក់ចំណេញសរុប

$(17 + 10) \times 20 = 540\$$

ទី3៖ ក. 81កែស ខ. 2 268 000 ៛ គ. 8 000៛

ទី4៖ ក. 50ដើម ខ. 52ដើម

ទី5៖ ចំនួនស្រូវពូជដែលក្រសួងកសិកម្មចែកលើកទី2

$3\ 375kg - 2\ 025 = 1\ 350kg$

ចំនួនស្រូវពូជដែលក្រសួងកសិកម្មចែកលើកទី3

$1\ 350kg + 1\ 350kg = 2\ 700kg$

ចំនួនស្រូវពូជដែលក្រសួងកសិកម្មចែកឱ្យទាំងបីលើក

$3\ 375 + 1\ 350kg + 2\ 700kg = 7\ 425kg$

កសិករក្នុងមួយគ្រួសារទទួលបានស្រូវពូជទម្ងន់

$7\ 425kg \div 135 = 55kg$

# ជំពូកទី៣

# ប្រមាណវិធីមានវង់ក្រចក

| | |
|---|---|
| **រយៈពេល** | 8ម៉ោ |
| **វត្ថុបំណងមេរៀន** | ធ្វើប្រមាណវិធីមានវង់ក្រចកបានត្រឹមត្រូវ។ |
| **ចំណងជើងមេរៀន** | |
| **មេរៀនទី1** | ប្រមាណវិធីមានវង់ក្រចក |
| **មេរៀនទី2** | ប្រមាណវិធីមានវង់ក្រចកនិងឃ្នាប |
| **មេរៀនទី3** | លំហាត់សាឡើងវិញ |
| **មេរៀនទី4** | ចំណោទ |

| | |
|---|---|
| **មេរៀនទី1** | **ប្រមាណវិធីមានវង់ក្រចក** |
| **រយៈពេល** | 2ម៉ោ |
| **វត្ថុបំណង** | គណនាប្រមាណវិធីមានវង់ក្រចកបានត្រឹមត្រូវ។ |
| **សម្ភារឧបទេស** | ស.ស. ទំព័រទី 34 ដល់ទំព័រទី35 |
| **ដំណើរការបង្រៀន** | មើលលំនាំនៃការបង្រៀនទំព័រ11 |
| **ចម្លើយ/កំណែលំហាត់** | **លំហាត់៖**<br>ក. 8 045 ខ. 3 678 គ. 28 817 ឃ. 49 169 ង. 106 572 ច. 282 500 ឆ. 500<br>ជ. 122 820<br>**ចំណោទ៖**<br>ទី1៖ 17 500៛<br>ទី2៖ 130ល<br>ទី3៖ 102m<br>ទី4៖ 74kg<br>ទី5៖ 1 139 400៛<br>ទី6៖ ថ្លៃលក់កំណាត់សំពត់ទាំងអស់<br>(5 500 × 25) + (5 300 × 12) + 15 000 = 216 100៛<br>ទី7៖ ថ្លៃទិញត្រីងៀតទាំងអស់<br>[(32 000 × 18) + (28 500 × 14) + (25 000 × 20)] – 82 000 = 1 393 000៛ |

| **មេរៀនទី2** | **ប្រមាណវិធីមានវង់ក្រចកនិងឃ្នាប** |
|---|---|
| **រយៈពេល** | 2ម៉ោ |
| **វត្ថុបំណង** | គណនាប្រមាណវិធីមានវង់ក្រចកនិងឃ្នាបបានត្រឹមត្រូវ។ |
| **សម្ភារឧបទេស** | ស.ស. ទំព័រទី 36 ដល់ទំព័រទី37 |
| **ជំណើរការបង្រៀន** | មើលលំនាំនៃការបង្រៀនទំព័រ11-12 |
| **ចម្លើយ/កំណែលំហាត់** | **លំហាត់៖**<br>ក. 3 925 ខ. 205 គ. 44 900 ឃ. 26 550 ង. 1 492 ច. 4 ឆ. 906 ជ. 637 750<br>**ចំណោទ៖**<br>ទី1៖ ចំនួនប្រាក់ដែលឈ្នួញនោះនៅសល់ 954 200៛<br>ទី2៖ ចំនួនប្រាក់ដែលកូនម្នាក់ៗទទួលបាន 166 200៛<br>ទី3៖ ចំនួនប្រាក់ដែលមីងម៉ៅនៅសល់ 230 300៛ |

| **មេរៀនទី3** | **លំហាត់សាឡើងវិញ** |
|---|---|
| **រយៈពេល** | 2ម៉ោ |
| **វត្ថុបំណង** | ដោះស្រាយលំហាត់និងចំណោទដែលទាក់ទងនឹងប្រមាណវិធីមានវង់ក្រចកនិងឃ្នាបបានត្រឹមត្រូវ។ |
| **សម្ភារឧបទេស** | ស.ស. ទំព័រទី 38 ដល់ទំព័រទី39 |
| **ចម្លើយ/កំណែលំហាត់** | **ទី1៖**<br>ក. $5\,465 = (50 \times 100) + (4 \times 100) + (6 \times 10) + 5$<br>ខ. $9\,321 = (90 \times 100) + (3 \times 100) + (2 \times 10) + 1$<br>គ. $84\,570 = (80 \times 1\,000) + (4 \times 1\,000) + (5 \times 100) + (7 \times 10)$<br>ឃ. $20\,080 = (20 \times 1\,000) + (5 \times 10) + (3 \times 10)$<br>**ទី2៖**<br>ក. $(2 + 2) \div (2 + 2) = 1$ (មាន2របៀប)<br>$(2 \div 2) + (2 - 2) = 1$<br>$(2 + 2) - (2 \div 2) = 3$ (មាន3របៀប)<br>$(2 + 2) \times 2 - 2 = 6$ (មាន2របៀប)<br>$[(2 \times 2) + 2] \times 2 = 12$<br>$(2+ 2) \times (2 + 2) = 16$<br>ខ. $(3 \div 3) + (3 \div 3) = 2$<br>$(3 \times 3) - (3 + 3) = 3$<br>$[(3 \times 3) + 3] \div 3 = 4$<br>$(3 \times 3) - (3 \div 3) = 8$ |


| | |
|---|---|
| | (3 ÷ 3) + (3 × 3) = 10<br>[(3 ÷ 3) + 3] × 3 = 12<br>[(3 + 3) × 3] – 3 = 15<br>[(3 × 3) × 3] – 3 = 24<br>(3 × 3 × 3) + 3 = 30<br>(3 + 3) × (3 + 3) = 36 |

| **មេរៀនទី4** | **ចំណោទ** |
|---|---|
| **រយៈពេល** | 2ម៉ោ |
| **វត្ថុបំណង** | ដោះស្រាយចំណោទប្រមាណវិធីមានវង់ក្រចកនិងឃ្នាបបានត្រឹមត្រូវ។ |
| **សម្ភារឧបទេស** | ស.ស. ទំព័រទី 40 |
| **ដំណើរការបង្រៀន** | មើលលំនាំនៃការបង្រៀនទំព័រ11-13 |
| **ចម្លើយ/កំណែល់ហាត់** | ទី1៖ មីងសនចំណេញបានប្រាក់<br>[(60 000៛ × 20) + (9 000៛ × 785)] – 4 000 000៛ = 4 265 000៛<br>ទី2៖ ប្រាក់លក់ប្រេងទាំង3ប្រភេទ<br>(4 600៛ × 315) + (4 800៛ × 235) + (4 300៛ × 205) = 3 458 500៛<br>គេចំណេញបានប្រាក់<br>(315 + 235 + 205) × 500៛ = 377 500៛<br>ទី3៖ ប្រវែងរបងដែលត្រូវធ្វើ<br>576m – 4m = 572m<br>ប្រាក់ដែលគាត់ត្រូវចំណាយទាំងអស់<br>(3 000៛ × 480) + [(500៛ × 572) × 4] + 15 000៛ = 2 599 000៛<br>ទី4៖ ចំនួនសិស្សចាស់ដែលនៅសល់<br>574ន - (5 + 7 + 45) = 517ន<br>ចំនួនសិស្សសរុបនៅក្នុងឆ្នាំសិក្សាថ្មី<br>517ន + 65ន = 582ន<br>ទី5៖ ក. (386ន ÷ 2) – 35 = 158ន<br>ខ. (386ន ÷ 2) + 35 = 228ន<br>គ. (158 × 2) + (228 × 3) = 1 000ក្បាល |

# ជំពូកទី៤

# ចំនួនទសភាគ

| | |
|---|---|
| **រយៈពេល** | 7ម៉ |
| **វត្ថុបំណងមេរៀន** | គណនាចំនួនទសភាគបានត្រឹមត្រូវ។ |
| **ចំណងជើងមេរៀន** | |
| **មេរៀនទី1** | អំណាននិងសំណេរចំនួនទសភាគ |
| **មេរៀនទី2** | ខ្នង់និងតម្លៃលេខតាមខ្នង់ |
| **មេរៀនទី3** | ការប្រៀបធៀបនិងរៀបលំដាប់ចំនួនទសភាគ |
| **មេរៀនទី4** | ការបង្គត់ចំនួនទសភាគជាចំនួនគត់ |
| **មេរៀនទី5** | ចំនួនទសភាគមានតម្លៃស្មើគ្នា |
| **មេរៀនទី6** | លំហាត់សាឡើងវិញ |

| | |
|---|---|
| **មេរៀនទី1** | **អំណាននិងសំណេរចំនួនទសភាគ** |
| **រយៈពេល** | 1ម៉ |
| **វត្ថុបំណង** | អាននិងសរសេរចំនួនទសភាគបានត្រឹមត្រូវ។ |
| **សម្ភារឧបទេស** | ស.ស. ទំព័រទី 42<br>រូបភាពនៅទំព័រទី42 |
| **ដំណើរការបង្រៀន** | មើលលំនាំនៃការបង្រៀនទំព័រ11-13 |
| **ចម្លើយ/កំណែលំហាត់** | ទី1៖ ក. $\frac{14}{100}=0.14$ , ខ. $\frac{108}{100}=1.08$<br>ទី2៖ ក. 0.5 អានថាសូន្យចុចប្រាំ។<br>ខ. 0.25 អានថាសូន្យចុចម្ភៃប្រាំ។<br>គ. 4.52 អានថាបួនចុចហាសិបពីរ។<br>ទី3៖<br><br> |

| | |
|---|---|
| **មេរៀនទី2** | **ខ្នង់និងតម្លៃលេខតាមខ្នង់** |
| **រយៈពេល** | 1ម៉ |

| | |
|---|---|
| **វត្ថុបំណង** | ប្រាប់ពីខ្ទង់និងតម្លៃលេខតាមខ្ទង់បានត្រឹមត្រូវ។ |
| **សម្ភារឧបទេស** | ស.ស. ទំព័រទី43<br>រូបភាពនៅទំព័រទី43 |
| **ដំណើរការបង្រៀន** | មើលលំនាំនៃការបង្រៀនទំព័រ11-13 |
